# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1282

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : បង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានហេដ្ឋារចនាសម្ព័ន្ធក្រោមដី

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/26 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/28 |

៣. ចំណាយគម្រោងសរុប $500,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

| | |
|---|---|
| RESPONSIBLE UNIT | General Department of Telecommunications |
| អង្គភាពទទួលខុសត្រូវ | អគ្គនាយកដ្ឋានទូរគមនាគមន៍ |

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ
បញ្ចកោណទី២. ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះជានាបានការផ្តល់ព័ត៌មានចាំបាច់នានាទាក់ទងទៅនឹងការជីកគាស់បណ្តាញ, ស្ថានភាពបណ្តាញ, ការគ្រប់គ្រងឱ្យបានពេញលេញនូវហេដ្ឋារចនាសម្ព័ន្ធរួមក្រោមដី,ចូលរួមការពារទ្រព្យសម្បត្តិឯកជននិងសាធារណៈ សំដៅកាត់បន្ថយផលប៉ះពាល់ជាអតិបរមានូវហេដ្ឋារចនាសម្ព័ន្ធរួមក្រោមដី។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

ប្រៃសណីយ៍ និងទូរគមនាគមន៍

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

រាជធានីភ្នំពេញ, គ្រប់ខេត្តក្រុង,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គម្រោងនេះ មានគោលបំណងជួយសម្រួលក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធរួមក្រោមដីដល់ប្រតិបត្តិការជីកគាស់កាយ ដើម្បីបញ្ចៀសនូវការកាត់ផ្តាច់ប្រព័ន្ធទឹកស្អាត, លូបង្ហូរកាកសំណល់, បណ្តាញ អគ្គិសនី, បណ្តាញខ្សែកាប្លិ៍អុបទិកនិងបំពង់ផ្សេងៗទៀតដែលកប់ក្រោមដី។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

-បង្កើតនិងរៀបចំនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យហេដ្ឋារចនាសម្ព័ន្ធរួមក្រោមដីដែលមានលក្ខណៈច្បាស់លាស់ អាចទាញយកទិន្នន័យនោះមកប្រើប្រាស់បានយ៉ាងមានប្រសិទ្ធភាពទៅតាមតម្រូវការ

-អភិវឌ្ឍនិងរៀបចំកម្មវិធីលើឧបករណ៍ឆ្លាតវៃសម្រាប់មន្ត្រីទទួលបន្ទុកផ្តល់ការអនុញ្ញាត ជីកគាស់ក្នុងការពិនិត្យផ្ទៀងផ្ទាត់និងចេញលិខិតអនុញ្ញាត

-អភិវឌ្ឍនិងរៀបចំកម្មវិធីលើឧបករណ៍ឆ្លាតវៃសម្រាប់ឱ្យប្រជាពលរដ្ឋអាចទាញយកទិន្នន័យ ដើម្បីទទួលបានព័ត៌មានទូទៅអំពីបណ្តាញហេដ្ឋារចនាសម្ព័ន្ធរួមក្រោមដី។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

គម្រោងនេះត្រូវបានចាត់ទុកជាគម្រោងអាទិភាព មានជាអាទិ៍:

-គម្រោងឆ្លើយតបទៅនឹងរបៀបវារៈគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

-ដើម្បីធានានូវសង្គតិភាពនៃការគ្រប់គ្រង និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួមក្រោមដីនៅក្នុងព្រះរាជាណា-ចក្រកម្ពុជា។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

-ស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធរួមក្រោមដី

-ស្ថាប័នមានសមត្ថកិច្ចផ្តល់ការអនុញ្ញាតក្នុងការជីកគាស់

-ប្រតិបត្តិករពាក់ព័ន្ធ

-សាធារណៈជន។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **មិនទានចាប់ផ្តើម** |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងនេះមិនមានផលប៉ះពាល់ដល់ផ្នែកបរិស្ថាននិងសង្គមទេ ប៉ុន្តែនឹងចូលរួមចំណែកបង្កើនការគាំទ្រលើសេវាសាធារណៈ និងការគ្រប់គ្រងព័ត៌មានហេដ្ឋារចនាសម្ព័ន្ធរួមជាតិតាមរយៈការប្រើប្រាស់កម្មវិធី ព្រមទាំងជួយសន្សំសំចៃថវិកាជាតិនិងការចំណាយមិនចាំបាច់ផ្សេងៗរបស់ពលរដ្ឋកម្ពុជា។

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**-កំពុងគាំទ្រ និងលើកកម្ពស់ឱ្យមានការចូលរួមពីស្ត្រី**
**-មិនប៉ះពាល់ដល់តួនាទីរបស់បុរស និងស្ត្រីឡើយ**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់ នៅក្នុងអណត្តិរបស់ខ្លួនក្នុងការអនុវត្តគម្រោង ប៉ុន្តែទាមទារការសហការពីអន្តរក្រសួង និងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីផ្តល់ព័ត៌មាន និងការផ្តល់សេវាដល់ប្រជាពលរដ្ឋ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**កំពុងស្វែងរកដៃគូវិនិយោគ។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**ធនាគារអភិវឌ្ឍន៍អាស៊ីនិងដៃគូវិនិយោគផ្សេងទៀតដែលមានលទ្ធភាពក្នុងការអនុវត្តគម្រោង។**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 200.0 | 200.0 | 100.0 | 500.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 50.0 | 50.0 | 20.0 | 120.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 40.0 | 30.0 | 15.0 | 85.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 100.0 | 100.0 | 50.0 | 250.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 10.0 | 10.0 | 20.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 10.0 | 10.0 | 5.0 | 25.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 200.0 | 200.0 | 100.0 | 500.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 ថវិកា | 2024 ជាក់ស្តែង | 2025 ថវិកា | 2026 ប៉ាន់ស្មាន | 2027 ប៉ាន់ស្មាន | 2028 ប៉ាន់ស្មាន | សរុប 2026-2028 | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Asian Development Bank | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 200.0 | 200.0 | 100.0 | 500.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: